# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ : ០៩១/២៥ ក.ប/ខ.ល**

## សារលិខិតអបអរសាទរ

**សូមគោរពជូន**

**ឯកឧត្តម ហ៊ី សោភា ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា**

***ជាទីគោរពដ៏ខ្ពង់ខ្ពស់!***

ក្នុងឱកាសដ៏សោមនស្សរីករាយនេះ តាងនាមថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្នុងនាមខ្ញុំបាទ និងភរិយា សូមសម្តែងនូវការអបអរសាទរជូនចំពោះ **ឯកឧត្តម ហ៊ី សោភា** ដែលត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញបោះឆ្នោតជាឯកច្ឆន្ទជ្រើសតាំងជា **ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា** សម្រាប់អាណត្តិ៣ឆ្នាំ លើកទី១០(២០២៥-២០២៨) នៅព្រឹកថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៥នេះ។

ការទទួលបាននូវការជ្រើសតាំងនេះ គឺជាកិត្តិយសដ៏ធំធេង និងស័ក្តិសមបំផុតសម្រាប់ **ឯកឧត្តម** ដែលបានបូជានូវកម្លាំងកាយ ប្រាជ្ញាស្មារតី ក្នុងការចូលរួមដឹកនាំក្រុមប្រឹក្សាធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឱ្យសម្រេចបាននូវសមិទ្ធផលជាបន្តបន្ទាប់ជូនជាតិមាតុភូមិ តាមរយៈការធានាធម្មនុញ្ញភាព និងនីតិរដ្ឋនៅកម្ពុជា បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការបម្រើឱ្យឧត្តមប្រយោជន៍ជាតិ និងប្រជាជននៅទូទាំងប្រទេស។

ឆ្លៀតក្នុងឱកាសដ៏ថ្លៃថ្លានេះ យើងខ្ញុំទាំងអស់គ្នា សូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ កែវទាំងបី វត្ថុស័ក្តិសិទ្ធក្នុងលោក ទេវតាថែរក្សាក្នុងព្រះរាជាណាចក្រកម្ពុជា សូមប្រោះព្រំសព្វសាធុការពរ សិរីសួស្តី ជ័យមង្គល វិបុលសុខ ជូនចំពោះ **ឯកឧត្តម** ព្រមទាំងក្រុមគ្រួសារជាទីស្រឡាញ់ សូមសមប្រកបដោយព្រះពុទ្ធពរបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តម ហ៊ី សោភា ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា** មេត្តាទទួលនូវគារវភក្តីភាពដ៏ស្មោះស្ម័គ្រពីយើងខ្ញុំទាំងអស់គ្នា។

ថ្ងៃព្រហស្បតិ៍ ១កើត ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៥

**តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**រដ្ឋមន្ត្រី**

**ហេង សួរ**

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩